ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០៧៥ ព.ម ការ

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧

# សេចក្តីសម្រេច
## ស្តីពីការផ្តល់សិទ្ធិពេញលេញជូនមន្ទីរព័ត៌មានរាជធានី-ខេត្ត

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- យោងតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៥ ស្តីពីការបន្តអនុវត្តនូវយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ លើកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈតាមប្រព័ន្ធវិមជ្ឈការ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង ក្នុងតំណាក់កាលថ្មី និងស្របតាមលទ្ធភាព សមត្ថភាព និងប្រសិទ្ធ-ភាពការងាររបស់មន្ទីរព័ត៌មានរាជធានី-ខេត្ត ។

## សម្រេច

**ប្រការ ១** : ត្រូវបានផ្ទេរ និងប្រគល់សិទ្ធិពេញលេញជូនគ្រប់មន្ទីរព័ត៌មានរាជធានី-ខេត្ត ក្នុងការចេញលិខិតបន្តអាជ្ញាប័ណ្ណជូនដល់គ្រប់ស្ថានីយ៍ វិទ្យុ ទូរទស្សន៍ អង្គការសារព័ត៌មានក្នុងស្រុក និងអង្គភាពបោះពុម្ពផ្សាយនានា ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងព័ត៌មាន ក្នុងក្របខណ្ឌដែនដីរាជធានី-ខេត្ត រៀងៗខ្លួន ។

**ប្រការ ២** : ការបង់ពន្ធ ការបង់ថ្លៃសេវាសាធារណៈ និងការបង់ថ្លៃសេវាសោតទស្សន៍របស់បណ្តាស្ថានីយ៍វិទ្យុ ទូរទស្សន៍ អង្គភាពប្រព័ន្ធផ្សព្វផ្សាយនានា ដែលមានកាតព្វកិច្ចបង់ពន្ធតាមច្បាប់កំណត់នោះ ក៏ត្រូវបង់ចូលថវិការដ្ឋតាមរយៈការិយាល័យផែនការ គណនេយ្យ និងហិរញ្ញកិច្ចនៃមន្ទីរព័ត៌មានរាជធានី-ខេត្ត នៅទីតាំងនោះ ។/

អាសយដ្ឋាន: អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ត្រូវសហការ និងជួយសម្រួលការងារ ដូចមានចែងក្នុងប្រការ១ និងប្រការ២ ជាមួយមន្ទីរព័ត៌មានរាជធានី-ខេត្ត ធានាបាននូវភាពរលូន តម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៤** : លិខិតបទដ្ឋានណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវបានចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃដែលបានចុះហត្ថលេខា នេះតទៅ ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី-ខេត្ត

  \- ដើម្បីជូនជ្រាប -
- អគ្គនាយកដ្ឋាននានាចំណុះក្រសួង
- មន្ទីរព័ត៌មានរាជធានី-ខេត្ត

  \- ដើម្បីអនុវត្ត -
- ឯកសារ, កាលប្បវត្តិ